- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១** : បង្កើត និងតែងតាំងគណៈកម្មការមួយមានឈ្មោះថា " គណៈកម្មការជ្រើសរើសភ្នាក់ងារគយ និងរដ្ឋាករ " ដែលមានសមាសភាពដូចខាងក្រោម ៖

១- ឯកឧត្តម **ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ **ប្រធាន**

២- ឯកឧត្តម **ជូ ចិវិត្ត** អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **អនុប្រធាន**

៣- ឯកឧត្តម **ហ៊ាន សាហ៊ីប** អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **អនុប្រធាន**

៤- លោក **ម៉ម និច** អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **អនុប្រធាន**

៥- លោក **មោក សុផារិន** ប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **អនុប្រធាន**

៦- លោក **សៀច ឈុនទ្រី** នាយករងទី១ ទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

៧- លោក **គុណ ញឹម** នាយករង ទីចាត់ការគយនិងរដ្ឋាករ **សមាជិកអចិន្ត្រៃយ៍**

៨- លោក **ស ថេង** នាយករង ទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

៩- លោក **ឡាយ ឫទ្ធី** នាយករង ទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

១០- លោក **ឯម ឃិនចរៈ** នាយករង ទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

១១- លោក **ប៉ែន សំអាត** ប្រធានការិយាល័យលេខាធិការនិងជំនួយការទីចាត់ការគយ និងរដ្ឋាករ **សមាជិក**

១២- លោក **ឆ៊ន ចាន់ថា** ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិកទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

១៣- លោក **ខៀវ សំអាន** ប្រធានការិយាល័យគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ **សមាជិក**

១៤- អស់លោក ជំនាញការគយអមទីចាត់ការគយនិងរដ្ឋាករ **ជាអ្នកសង្កេតការណ៍និងផ្តល់យោបល់**

១៥- លោក **ប៊ូ ប៊ុនណារ៉ា** ជំនួយការការិយាល័យបច្ចេកទេសគយ **លេខាធិការ**

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

- ចាត់ចែង កសាងគោលការណ៍ចាំបាច់នានាពាក់ពន្ធ័នឹងការងារជ្រើសរើស ភ្នាក់ងារគយ និងរដ្ឋាករ មានជាអាទិ ការកំណត់លក្ខណៈសម្បត្តិ និងជ្រើសរើសបេក្ខជន ការរៀបចំមណ្ឌលប្រឡង ការកំណត់កម្មវត្ថុនៃការប្រឡង ការវាយតំលៃបេក្ខជនមុន និងក្រោយការប្រឡង ការត្រៀមហិរញ្ញ ការត្រៀមផ្ទេរ ឬបញ្ចូលក្របខ័ណ្ឌដើម្បីឆ្លើយតបតាមសំណូមពរនៃការជ្រើសរើស ។
- ទំនាក់ទំនងជាមួយ ក្រសួង ស្ថាប័ន និងអង្គការជំនាញពាក់ពន្ធ័ ដើម្បីសុំកិច្ចសហការ និងការចូលរួមក្នុងដំណើរការការងារជ្រើសរើសមន្ត្រីរាជការគយនិងរដ្ឋាករនេះ ក្នុងករណីយល់ថាចាំបាច់។

- ធ្វើរបាយការណ៍ជាប្រចាំនូវការវិវត្តន៍ និងលទ្ធផលដែលទទួលបានតាមដំណាក់ទីមួយៗ នៃការងារនេះជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- បង្កើតអនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដើម្បីទទួលបន្ទុកចាត់ចែង អនុវត្តនូវភារកិច្ចដោយឡែកៗពីគ្នា ក្នុងគោលបំណងធានាប្រសិទ្ធភាព តំលាភាព និងភាពគ្រប់ជ្រុងជ្រោយនៃការងារនេះ ។

**ប្រការ ៣ :** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការនាយកដ្ឋាន និងអង្គភាពពាក់ពន្ធ័នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាម៉ីជនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- នាយកខុទ្ទកាល័យ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- នាយកដ្ឋានបុគ្គលិក ( ដើម្បីជូនជ្រាប )
- ដូចប្រការ៣ ( ដើម្បអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១០៥ សហវ.ប្រក.

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពី

## ការកែសម្រួលអត្រាពន្ធគយលើទំនិញនាំចូលមួយចំនួន

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៩៤៤ សហវ.ប្រក.គរ. ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០០៤

- បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៥ លើលិខិតលេខ ៧២៤៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការលើកទឹកចិត្តដល់ផលិតករក្នុងស្រុក ។

**សម្រេច :**

**ប្រការ១ :** ត្រូវបានកែសម្រួលអត្រាពន្ធគយលើមុខទំនិញនាំចូលមួយចំនួន ដែលមានចែងនៅក្នុងតារាងពន្ធគយកម្ពុជាជាធរមាន ដូចខាងក្រោមនេះ ÷

ក- សូន្យភាគរយ (០%) សម្រាប់បណ្តាមុខទំនិញដែលមានទីតាំងរងដូចខាងក្រោមនេះ :

1301.10.00 ; 1301.20.00 ; 3901.10.10 ; 3901.10.21 ; 3901.10.22 ; 3901.10.23; 3901.10.29 ; 3901.10.30 ; 3901.10.91 ; 3901.10.99 ; 3901.20.10 ; 3901.20.21; 3901.20.22 ; 3901.20.29 ; 3901.20.30 ; 3901.20.90 ; 3901.30.10 ; 3901.30.20; 3901.30.30 ; 3901.30.90 ; 3901.90.10 ; 3901.90.20 ; 3901.90.30 ; 3901.90.90; 3902.10.10 ; 3902.10.21 ; 3902.10.29 ; 3902.10.30 ; 3902.10.91 ; 3902.10.99; 3902.20.10 ; 3902.20.20 ; 3902.20.30 ; 3902.20.90 ; 3902.30.10 ; 3902.30.21; 3902.30.29 ; 3902.30.30 ; 3902.30.91 ; 3902.30.99 ; 3902.90.10 ; 3902.90.20; 3902.90.30 ; 3902.90.90 ; 3903.11.10 ; 3903.11.20 ; 3903.11.30 ; 3903.11.90; 3903.19.10 ; 3903.19.20 ; 3903.19.30 ; 3903.19.90 ; 3903.20.10 ; 3903.20.20; 3903.20.30 ; 3903.20.40 ; 3903.20.90 ; 3903.30.10 ; 3903.30.20 ; 3903.30.30; 3903.30.40 ; 3903.30.90 ; 3903.90.10 ; 3903.90.20 ; 3903.90.30 ; 3903.90.40; 3903.90.90 ; 3904.10.10 ; 3904.10.20 ; 3904.10.31 ; 3904.10.39 ; 3904.10.40; 3904.10.90 ; 3904.21.10 ; 3904.21.21 ; 3904.21.29 ; 3904.21.30 ; 3904.21.90; 3904.22.10 ; 3904.22.21 ; 3904.22.29 ; 3904.22.30 ; 3904.22.90 ; 3904.30.10; 3904.30.21 ; 3904.30.29 ; 3904.30.90 ; 3904.40.10 ; 3904.40.21 ; 3904.40.29; 3904.40.90 ; 3904.50.10 ; 3904.50.20 ; 3904.50.30 ; 3904.50.90 ; 3904.61.10; 3904.61.20 ; 3904.61.90 ; 3904.69.10 ; 3904.69.20 ; 3904.69.90 ; 3904.90.10; 3904.90.20 ; 3904.90.90 ; 3905.12.00 ; 3905.19.10 ; 3905.19.90 ; 3905.21.00; 3905.29.10 ; 3905.29.90 ; 3905.30.10 ; 3905.30.20 ; 3905.30.90 ; 3905.91.10; 3905.91.90 ; 3905.99.11 ; 3905.99.19 ; 3905.99.90 ; 3906.10.10 ; 3906.10.20; 3906.10.90 ; 3906.90.11 ; 3906.90.12 ; 3906.90.19 ; 3906.90.91 ; 3906.90.92; 3906.90.99 ; 3907.10.10 ; 3907.10.20 ; 3907.10.90 ; 3907.20.11 ; 3907.20.19; 3907.20.90 ; 3907.30.10 ; 3907.30.20 ; 3907.30.30 ; 3907.30.90 ; 3907.40.10; 3907.40.20 ; 3907.40.90 ; 3907.50.10 ; 3907.50.90 ; 3907.60.10 ; 3907.60.20; 3907.60.90 ; 3907.91.10 ; 3907.91.90 ; 3907.99.10 ; 3907.99.20 ; 3907.99.30; 3907.99.40 ; 3907.99.90 ; 3908.10.11 ; 3908.10.12 ; 3908.10.19 ; 3908.10.91; 3908.10.92 ; 3908.10.99 ; 3908.90.10 ; 3908.90.20 ; 3908.90.90 ; 3909.10.10; 3909.10.90 ; 3909.20.10 ; 3909.20.90 ; 3909.30.10 ; 3909.30.90 ; 3909.40.10; 3909.40.90 ; 3909.50.00 ; 3910.00.11 ; 3910.00.19 ; 3910.00.90 ; 3911.10.10; 3911.10.90 ; 3911.90.10 ; 3911.90.90 ; 3912.11.00 ; 3912.12.00 ; 3912.20.10;

3912.20.20 ; 3912.31.00 ; 3912.39.00 ; 3912.90.10 ; 3912.90.20 ; 3912.90.90; 3913.10.00 ; 3913.90.00 ; 3914.00.00 ; 7201.10.00 ; 7201.20.00 ; 7201.50.00; 7202.11.00 ; 7202.19.00 ; 7202.21.00 ; 7202.29.00 ; 7202.30.00 ; 7202.41.00; 7202.49.00 ; 7202.50.00 ; 7202.60.00 ; 7202.70.00 ; 7202.80.00 ; 7202.91.00; 7202.92.00 ; 7202.93.00 ; 7202.99.00 ; 7203.10.00 ; 7203.90.00 ; 7205.10.00; 7205.21.00 ; 7205.29.00 ; 7206.10.00 ; 7206.90.10 ; 7206.90.90 ; 7208.10.10; 7208.10.20 ; 7208.10.30 ; 7208.10.90 ; 7208.25.10 ; 7208.25.91 ; 7208.25.99; 7208.26.10 ; 7208.26.90 ; 7208.27.11 ; 7208.27.19 ; 7208.27.91 ; 7208.27.99; 7208.36.00 ; 7208.37.10 ; 7208.37.90 ; 7208.38.10 ; 7208.38.90 ; 7208.39.11; 7208.39.19 ; 7208.39.90 ; 7208.40.00 ; 7208.51.00 ; 7208.52.00 ; 7208.53.00; 7208.54.00 ; 7208.90.10 ; 7208.90.20 ; 7208.90.30 ; 7208.90.90 ; 7209.15.00; 7209.16.00 ; 7209.17.00 ; 7209.18.10 ; 7209.18.90 ; 7209.25.00 ; 7209.26.00; 7209.27.00 ; 7209.28.00 ; 7209.90.00 ; 7210.11.00 ; 7210.12.00 ; 7210.20.00; 7210.30.11 ; 7210.30.19 ; 7210.30.91 ; 7210.30.99 ; 7210.49.10 ; 7210.49.90; 7210.50.00 ; 7210.61.10 ; 7210.61.90 ; 7210.69.10 ; 7210.69.90 ; 7210.70.11; 7210.70.12 ; 7210.70.20 ; 7210.70.30 ; 7210.70.40 ; 7210.70.50 ; 7210.70.60; 7210.70.70 ; 7210.70.90 ; 7210.90.11 ; 7210.90.12 ; 7210.90.20 ; 7210.90.30; 7210.90.40 ; 7210.90.50 ; 7210.90.60 ; 7210.90.70 ; 7210.90.90 ; 7218.10.00; 7218.91.00 ; 7218.99.00 ; 7219.11.10 ; 7219.11.90 ; 7219.12.10 ; 7219.12.90; 7219.13.10 ; 7219.13.90 ; 7219.14.10 ; 7219.14.90 ; 7219.21.00 ; 7219.22.00; 7219.23.00 ; 7219.24.00 ; 7219.31.00 ; 7219.32.00 ; 7219.33.00 ; 7219.34.00; 7219.35.00 ; 7224.10.00 ; 7224.90.00 ; 7225.11.00 ; 7225.19.00 ; 7225.20.00; 7225.30.10 ; 7225.30.21 ; 7225.30.29 ; 7225.30.91 ; 7225.30.99 ; 7225.40.00; 7225.50.00 ; 7225.91.00 ; 7225.92.00 និង 7225.99.00 ។

ខ- ប្រាំពីរភាគរយ (7%) សម្រាប់បណ្តាមុខទំនិញដែលមានទីតាំងរងដូចខាងក្រោមនេះ :

4101.20.00 ; 4101.50.00 ; 4101.90.00 ; 4102.10.00 ; 4102.21.00 ; 4102.29.00; 4103.10.00 ; 4103.20.00 ; 4103.30.00 ; 4103.90.00 ; 4104.11.10 ; 4104.11.20; 4104.11.90 ; 4104.19.10 ; 4104.19.20 ; 4104.19.90 ; 4104.41.10 ; 4104.41.90; 4104.49.10 ; 4104.49.90 ; 4105.10.10 ; 4105.10.20 ; 4105.10.30 ; 4105.10.90; 4105.30.00 ; 4106.21.10 ; 4106.21.20 ; 4106.21.90 ; 4106.22.00 ; 4106.31.10; 4106.31.90 ; 4106.32.10 ; 4106.32.90 ; 4106.40.10 ; 4106.40.20 ; 4106.40.90; 4106.91.10 ; 4106.91.90 ; 4106.92.10 ; 4106.92.90 ; 4107.11.00 ; 4107.12.00; 4107.19.00 ; 4107.91.00 ; 4107.92.00 ; 4107.99.00 ; 4112.00.00 ; 4113.10.00; 4113.20.00 ; 4113.30.00 ; 4113.90.00 ; 4114.10.00 ; 4114.20.00 ; 4115.10.00; 4115.20.00 ; 4401.10.00 ; 4401.21.00 ; 4401.22.00 ; 4401.30.00 ; 4402.00.00; 4404.10.00 ; 4404.20.00 ; 4405.00.00 ; 4406.10.00 ; 4406.90.00 ; 4407.10.10; 4407.10.20 ; 4407.10.90 ; 4407.24.10 ; 4407.24.20 ; 4407.24.90 ; 4407.25.11; 4407.25.12 ; 4407.25.19 ; 4407.25.21 ; 4407.25.22 ; 4407.25.29 ; 4407.26.10; 4407.26.20 ; 4407.26.90 ; 4407.29.11 ; 4407.29.12 ; 4407.29.19 ; 4407.29.21; 4407.29.22 ; 4407.29.29 ; 4407.29.31 ; 4407.29.32 ; 4407.29.39 ; 4407.29.41; 4407.29.42 ; 4407.29.49 ; 4407.29.51 ; 4407.29.52 ; 4407.29.59 ; 4407.29.61;

4407.29.62 ; 4407.29.63 ; 4407.29.69 ; 4407.29.71 ; 4407.29.72 ; 4407.29.79; 4407.29.81 ; 4407.29.82 ; 4407.29.89 ; 4407.29.91 ; 4407.29.92 ; 4407.29.93; 4407.29.94 ; 4407.29.95 ; 4407.29.99 ; 4407.91.10 ; 4407.91.20 ; 4407.91.90; 4407.92.10 ; 4407.92.20 ; 4407.92.90 ; 4407.99.10 ; 4407.99.20 ; 4407.99.30; 4407.99.40 ; 4407.99.90 ; 4408.10.10 ; 4408.10.20 ; 4408.10.30 ; 4408.10.90; 4408.31.10 ; 4408.31.90 ; 4408.39.10 ; 4408.39.20 ; 4408.39.90 ; 4408.90.10; 4408.90.20 ; 4408.90.90 ; 8545.11.00 និង 8545.19.00 ។

**ប្រការ២ :** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣ :** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ព្រមទាំងអង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឱ្យមានប្រសិទ្ធភាព ចំពោះទំនិញប្រភេទដូចរៀបរាប់ខាងលើ ដែលបំពេញបែបបទចុះបញ្ជិកាប្រតិវេទន៍លំអិតដើម្បីនាំចូល ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ នេះតទៅ ។

<u>ចម្លងជូន</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី ( ដើម្បីជូនជាព័ត៌មាន)
- ទីចាត់ការគយ និង រដ្ឋាករ
- សភាពាណិជ្ជកម្ម ( ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ : ០៨៩ ប្រក.កសក

# ប្រកាស

## ស្តីពី

## ផល អនុផលព្រៃឈើដែលត្រូវហាមឃាត់ការប្រមូលផល

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងព្រៃសម្បទាន
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជា រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សម្រេច

**ប្រការ ១ :** ហាមឃាត់ការប្រមូលផល អនុផលព្រៃឈើនៅក្នុងព្រៃធម្មជាតិនៃព្រៃបំរុងទុកអចិន្ត្រៃយ៍គ្រប់ប្រភេទ ដូចមានកំណត់ខាងក្រោម :

១- ប្រភេទឈើជាប់ក្នុងលំដាប់ថ្នាក់ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ

២- ប្រភេទឈើដែលមានដោយកម្រ

៣- ប្រភេទឈើដែលប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី

៤- ដើមឈើផ្តល់ជ័រមានតំលៃ ។

ការប្រមូលផល អនុផលព្រៃឈើក្នុងកថាខ័ណ្ឌទី ១ ខាងលើ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ២ :** ប្រភេទឈើដែលអនុញ្ញាតឱ្យកាប់រំលំក្នុងដំណើរការប្រមូលផលក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍ ត្រូវបានចាត់ថ្នាក់តាមលំដាប់ថ្នាក់ និង កំណត់អង្កត់ផ្ចិតអប្បបរមាវាស់នៅត្រង់គល់កំពស់ ១.៣០ម ពីដី ឬ កំពស់ ០.៣០ម លើឫសព្រីង ស្របតាមការលូតលាស់ និងបច្ចេកទេសរុក្ខវប្បកម្មសំរាប់ប្រភេទឈើនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី I នៃប្រកាសនេះ ។

**ប្រការ ៣ :** ចំពោះកូនឈើដែលមានទំហំអង្កត់ផ្ចិតក្រោម ៣០សម អាចអនុញ្ញាតឱ្យប្រមូលផលតាមកម្រិតកំណត់នៃផែនការ និងតាមប្រភេទឈើដែលត្រូវសំរេចដោយ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៤ :** ការប្រមូលផលប្រភេទឈើម៉ៃសាក់ ប្រភេទឈើស្រល់ និងប្រភេទឈើផ្សេងទៀត ដែលបានធ្វើការដាំដុះជាចំការព្រៃដាំរបស់រដ្ឋ ត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៥ :** ការកែច្នៃ ឬចាំងឈើហ៊ុបមូលទៅជាឈើហ៊ុបជ្រុងនៅក្នុងព្រៃបំរុងទុកអចិន្ត្រៃយ៍ ត្រូវហាមឃាត់ ហើយរាល់ឈើហ៊ុបជ្រុងទាំងនោះ ត្រូវបានចាត់ទុកជាឈើល្មើសច្បាប់ ។

**ប្រការ ៦ :** ក្នុងដំណើរការប្រមូលផល រាល់ឈើហ៊ុបមូលដែលមានអង្កត់ផ្ចិតក្រោមទំហំអប្បបរមាតាមប្រភេទឈើ ដូចមានចែងក្នុងឧបសម្ព័ន្ធទី I នៃប្រការ ២ ខាងលើ មានជាអាទិ៍ កំណាត់ឈើហ៊ុបដែលបានមកពីការបើកផ្លូវឹកជញ្ជូន-អូសទាញ បានមកពីការដកហូតតាមបច្ចេកទេសរុក្ខវប្បកម្ម បានមកពីការដួលរំលំដោយប្រភេទឈើធំៗដួលសង្កត់ក្នុងពេលប្រមូលផល ឬ ក្នុងឧប្បទ្ទវហេតុផ្សេងៗទៀត ។ល។ ត្រូវមានកំណត់ហេតុច្បាស់លាស់ និងមានការឯកភាពរបស់នាយផ្នែករដ្ឋបាលព្រៃឈើសាមី ។

**ប្រការ ៧ :** ត្រូវបានចាត់ទុកជាប្រភេទឈើមានដោយកម្រ ចំពោះប្រភេទរុក្ខជាតិព្រៃឈើទាំងឡាយណា ដែលមានអត្រារបាយទាប ការបន្តពូជក្នុងធម្មជាតិមានសក្តានុពលទាប កម្រជួបប្រទះក្នុងប្រព័ន្ធមជ្ឈដ្ឋាននៃព្រៃបំរុងទុកអចិន្ត្រៃយ៍ មានតម្លៃផ្នែកវិទ្យាសាស្ត្រ សេដ្ឋកិច្ច-សង្គម វប្បធម៌ និងអាចប្រឈមមុខចំពោះការគំរាមកំហែង ឬ ផុតពូជ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី II នៃប្រកាសនេះ ។

**ប្រការ ៨ :** ប្រភេទឈើដែលប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី គឺសំដៅទៅលើដើមឈើផ្តល់ជ័រទឹកដែលធ្លាប់បាន និងកំពុងកាន់កាប់ ឬប្រើប្រាស់ជាលក្ខណៈប្រពៃណី ដោយប្រជាជនសហគមន៍មូលដ្ឋានក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី III នៃប្រកាសនេះ ។

**ប្រការ ៩ :** អាចអនុញ្ញាតឱ្យចោះយកជ័របាន ចំពោះដើមឈើទាលដែលដុះក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ លុះត្រាតែមានអង្កត់ផ្ចិតចាប់ពី ៤៥សម ឡើងទៅវាស់នៅត្រង់កំពស់ ១.៣០ម ពីដី ។

ការប្រមូលផលដើមឈើដែលប្រជាជនសហគមន៍មូលដ្ឋានចោះយកជ័រតាមប្រពៃណី នៅក្នុងព្រៃគុប ទោះជាដើមឈើទាលដែលមានអង្កត់ផ្ចិតចាប់ពី ១២០សម ឡើងទៅក៏ដោយ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការព្រមព្រៀង និង យល់ព្រមពីម្ចាស់ដើមឈើផ្តល់ជ័រនោះ ។

**ប្រការ ១០ :** ដើមឈើផ្តល់ជ័រមានតំលៃ គឺសំដៅលើប្រភេទដើមឈើដែលអាចផ្តល់ជ័រ ឬទ្រទ្រង់ជ័រល័ក្ខ ដែលមានតម្លៃផ្នែកវិទ្យាសាស្ត្រ សេដ្ឋកិច្ច-សង្គម និង វប្បធម៌ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី IV នៃប្រកាសនេះ ។

**ប្រការ ១១ :** ប្រភេទឈើទាំងឡាយណាដែលគ្មានចែងក្នុងបញ្ជីឈ្មោះកំណត់ក្នុងឧបសម្ព័ន្ធទី I, ទី II, ទី III, និង ទី IV នៃប្រកាសនេះ រដ្ឋបាលព្រៃឈើត្រូវខិតខំស្រាវជ្រាវ សិក្សាបន្ថែម ដើម្បីស្នើសុំបញ្ចូលក្នុងតារាងចំណាត់ថ្នាក់ពាក់ព័ន្ធជាចាំបាច់ ។

ផល អនុផលព្រៃឈើទាំងអស់ ដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី I, ទី II, ទី III, និងទី IV នៃប្រកាសនេះ អាចពិនិត្យកែប្រែឡើងវិញតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ចំពោះប្រភេទឈើទាំងឡាយណាដែលមិនមានចែងក្នុងតារាងឧបសម្ព័ន្ធទី I នៃប្រការ ២ ខាងលើនេះ ត្រូវបានចាត់ទុកជាប្រភេទឈើមិនទាន់ចាត់ថ្នាក់ ។

**ប្រការ ១២ :** ជនណាប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីព្រៃឈើ ។

**ប្រការ ១៣ :** ប្រកាស ឬសេចក្តីសំរេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១៤ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និងប្រធានអង្គភាព ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

**រដ្ឋមន្ត្រី**

**ចាន់-សារុន**

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ ១៤
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី I ភ្ជាប់ប្រកាសលេខ .០៨៥.......... ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

## ប្រភេទឈើជាប់ក្នុងលំដាប់ថ្នាក់ និង ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ

| ល.រ | លេខកូដ | ឈ្មោះខ្មែរ | ឈ្មោះពាណិជ្ជកម្ម ក្នុងស្រុក ឬ តំបន់ | ឈ្មោះវិទ្យាសាស្ត្រ | | ទំហំអប្បបរមា អនុញ្ញាតឱ្យកាប់រំលំ |
|---|---|---|---|---|---|---|
| | | | | ប្រភេទ | អំបូរ | |
| | | | **ឈើប្រណីត** | | | |
| ១ | 0.1 | អង្កាញ់ | Angkanh / Cassia | Cassia siamea, Lam. | Caesalpiniaceae | 0.៤៥ ម |
| ២ | 0.2 | អង្កត់ខ្មៅ | Angkat khmau / Kayu Malam / Ebony | Diospyros bejaudi, Lec. | Ebenaceae | 0.៤៥ ម |
| ៣ | 0.3 | បេង | Beng / Afzelia | Afzelia xylocarpa, (Kurz) Craib | Caesalpiniaceae | 0.៤៥ ម |
| ៤ | 0.4 | ឈើខ្មៅ | Chhoeu khmau / Kayu Malam / Ebony | Diospyros sp. | Ebenaceae | 0.៤៥ ម |
| ៥ | 0.5 | ជើងចាប | Choeng chap / Mempisang / Karai | Dasymachalon lomentaceum, Fin.& Gagn. | Annonaceae | 0.៤៥ ម |
| ៦ | 0.6 | ច្រេស | Chres / Albizia | Albizia lebbeck, (L.) Benth | Mimosaceae | 0.៤៥ ម |
| ៧ | 0.7 | ហៃសាន ឬ ចាន់ស | Haisan / Chansor | Cassia garretiana, Craib | Caesalpiniaceae | 0.៤៥ ម |
| ៨ | 0.8 | ហ៊ុនដាង ឬ ម្រះព្រៅភ្នំ | Hundang / Mreah prau phnom / Cedar white | Dysoxylum loureiri, Pierre | Meliaceae | 0.៤៥ ម |
| ៩ | 0.9 | ក្រញូង | Kranhung / Tulipwood / Burma | Dalbergia cochinchinensis, Pierre | Papilionaceae | 0.៤៥ ម |
| ១០ | 0.10 | ក្រើល | Kroeul / Rengas / Machang | Melanorrhea laccifera, Pierre | Anacardiaceae | 0.៤៥ ម |
| ១១ | 0.11 | នាងនួន ឬ លាំង | Neang noun / Camiai / Tulipwood / Burma | Dalbergia bariensis, Pierre | Papilionaceae | 0.៤៥ ម |
| ១២ | 0.12 | តាត្រាវ | Tatrao / Tembusu / Anan | Fagraea fragrans, Roxb. | Loganiaceae | 0.៤៥ ម |
| ១៣ | 0.13 | ថ្នង់ | Thnong / Padauk | Pterocarpus pedatus, Pierre | Papilionaceae | 0.៤៥ ម |
| ១៤ | 0.14 | ត្រយឹង | Trayoeung / Kayu Malam / Ebony | Diospyros helferi, C.B.Clarke | Ebenaceae | 0.៤៥ ម |
| | | | **ឈើលេខ ១** | | | |
| ១៥ | 1.1 | បូសនាគ | Bosneak / Pcnaga / Mesua | Mesua ferrea, L. | Guttiferae | 0.៣០ម |
| ១៦ | 1.2 | ស្ដី | Sdey | Crudia chrysantha, (Pierre) Schum. | Caesalpiniaceae | 0.៣០ម |

| | | | | | | |
|---|---|---|---|---|---|---|
| ១៧ | 1.3 | សំព័រ | Sompor / Keledang | Artocarpus sempervirens | Moraceae | 0.៣៥ម |
| ១៨ | 1.4 | ស្រឡៅ ឬ ឥន្ទនេល | Sralao / Enthenel / Peyinma / Benteak | Lagerstroemia sp. | Lythraceae | 0.៣៥ម |
| ១៩ | 1.5 | ត្រសេក ឬ ត្រាំកង់ | Trasek / Tramkang | Peltophorum ferrugineum, Benth. | Caesalpiniaceae | 0.៣៥ម |
| ២០ | 1.6 | ទ្រាល | Treal | Peltophorum dasyrachis(Miq.) Kurz | Caesalpiniaceae | 0.៣៥ម |
| ២១ | 1.7 | បេឡឺយ | Beleuy / Medang | Litsea vang, H.Lec. | Lauraceae | 0.៤៥ម |
| ២២ | 1.8 | ដូនចែម ឬ បីសន្លឹក | Daunchem / Beisanleuk / Mengkulang | Tarrietia javanica, Bl. | Sterculiaceae | 0.៤៥ម |
| ២៣ | 1.9 | កែស | Kes / Nyatou / Bitis | Manilkara hexandra, (Roxb.) Dub. | Sapotaceae | 0.៤៥ម |
| ២៤ | 1.10 | កកោះ | Kakah / Sepetir | Sindora cochinchinensis, Baill. | Caesalpiniaceae | 0.៤៥ម |
| ២៥ | 1.11 | ក្រឡាញ់ | Kralanh / Keranji | Dialium cochinchinensis, Pierre | Caesalpiniaceae | 0.៤៥ម |
| ២៦ | 1.12 | ម៉ៃសាក់ | Maisak / Teak | Tectona grandis, L.f. | Verbenaceae | 0.៤៥ម |
| ២៧ | 1.13 | ផ្ចឹក | Phchek / Meranti / Balau | Shorea obtusa, Woll. | Dipterocarpaceae | 0.៤៥ម |
| ២៨ | 1.14 | ផ្កាយព្រឹក | Phkay preuk / Ipil | Afzelia bijuga, (Colebr.) A.Gray | Caesalpiniaceae | 0.៤៥ម |
| ២៩ | 1.15 | ពពូល ឬ ភ្លេល | Popoul / Phnel | Vitex sp. | Verbenaceae | 0.៤៥ម |
| ៣០ | 1.16 | រាំងភ្នំ | Raing phnom / Meranti | Shorea siamensis, Miq. | Dipterocarpaceae | 0.៤៥ម |
| ៣១ | 1.17 | សង្កួតម្អាត | Sangkuothmat | Stereospermum chelonoides (non L.Dop) | Bignoniaceae | 0.៤៥ម |
| ៣២ | 1.18 | សុក្រម | Sokram / Pyinkado | Xylia dolabriformis, Benth. | Mimosaceae | 0.៤៥ម |
| ៣៣ | 1.19 | ស្មែ | Sme / Poga | Ceriops roxburghiana, Arn. | Rhizophoraceae | 0.៤៥ម |
| ៣៤ | 1.20 | ឈ្លីក | Chhlik / Ketapang / Laurel | Terminalia alata, F. Heyne ex Roth | Combretaceae | 0.៤៥ម |
| ៣៥ | 1.21 | គគីរដែក | Koki dek / Giam / Merawan | Hopea helferi, Brandis | Dipterocarpaceae | 0.៥០ម |
| ៣៦ | 1.22 | គគីរម្សៅ | Koki masau / Giam / Merawan | Hopea odorata, Roxb. | Dipterocarpaceae | 0.៥០ម |
| ៣៧ | 1.23 | គគីរថ្ម | Koki thmor / Giam / Merawan | Hopea ferrea, Pierre | Dipterocarpaceae | 0.៥០ម |
| ៣៨ | 1.24 | ពពេល | Popel / Giam / Merawan | Shorea roxburghii, G.Don. | Dipterocarpaceae | 0.៥០ម |
| ៣៩ | 1.25 | វល្លិយោង | Voryaung / Chicrassy | Chukrasia tabularis, Ant. Juss. | Meliaceae | 0.៦០ម |

| ឈើលេខ ២ | | | | | | |
|---|---|---|---|---|---|---|
| ៤០ | 2.1 | ឆាំឆា | Chhamchha / Cedar | Toona febrifuga, M.Roem | Meliaceae | 0.៣០ម |
| ៤១ | 2.2 | ច្រម៉ាស់ | Chramas / Resak | Vatica astrotricha, Dyer. | Dipterocarpaceae | 0.៣០ម |
| ៤២ | 2.3 | ស្រគុំ | Srakum / Nyatoh / Payena | Payena elliptica, Lecomte | Sapotaceae | 0.៣០ម |
| ៤៣ | 2.4 | ទទឹមព្រៃ | Totem prey | | | 0.៣០ម |
| ៤៤ | 2.5 | ត្រឡាត់ | Tralat / Resak | Vatica philastreana, Pierre | Dipterocarpaceae | 0.៣០ម |
| ៤៥ | 2.6 | អាទិត្យ ឬ នាងផ្អែក | Atith / Medang | Hassia cuneata, Blume | Lauraceae | 0.៤៥ម |
| ៤៦ | 2.7 | ខ្ចៅ.កំលែង ឬ ផ្ចឹកអូដ៊ំ | Khchov / Komleng / Phchek audom / Meranti | Shorea thorelli, Pierre | Dipterocarpaceae | 0.៤៥ម |
| ៤៧ | 2.8 | គគីរខ្សាច់ | Koki khsach / Giam | Hopea pierrei, Pierre | Dipterocarpaceae | 0.៤៥ម |
| ៤៨ | 2.9 | គគីរភ្នង ឬ កំញាន | Koki phnong / Kom nhan / Meranti | Shorea hypochra, Hance | Dipterocarpaceae | 0.៤៥ម |
| ៤៩ | 2.10 | លំបោ | Lumbor / Meranti | Shorea. farinosa, C.Fisch. | Dipterocarpaceae | 0.៤៥ម |
| ៥០ | 2.11 | ផ្ដៀក | Phdiek / Mersawa / Krabak | Anisoptera costata, Korth. | Dipterocarpaceae | 0.៤៥ម |
| ៥១ | 2.12 | ស្រល់ | Sral / Pine | Pinus merkusii, Jungh & de Vries | Pinaceae | 0.៤៥ម |
| ៥២ | 2.13 | ស្រូលស | Sraul sar / Podo / Sempilor | Podocarpus imbricatus, Blume | Podocarpaceae | 0.៤៥ម |
| ៥៣ | 2.14 | ស្រូលក្រហម | Sraul kraham / Podo / Sempilor | Dacrydium elatum, Wall. ex Hook. | Podocarpaceae | 0.៤៥ម |
| ៥៤ | 2.15 | ថ្បែង | Thbeng / Keruing | Dipterocarpus obtusifolius, Teysm. | Dipterocarpaceae | 0.៤៥ម |
| ៥៥ | 2.16 | ខ្វាវ | Khvao / Haldu | Adina cordifolia, Hook.f. | Rubiaceae | 0.៤៥ម |
| ៥៦ | 2.17 | ខ្លង | Khlong / Keruing | Dipterocarpus tuberculatus, Roxb. | Dipterocarpaceae | 0.៥០ម |
| ៥៧ | 2.18 | ត្រាច | Trach / Keruing | Dipterocarpus intricatus, Dyer. | Dipterocarpaceae | 0.៥០ម |
| ៥៨ | 2.19 | ឈើទាលបង្គួយ ឬ ឈើទាលនាងវែង | Chhoeuteal / Keruing | Dipterocarpus costatus, Gaertn. | Dipterocarpaceae | 0.៦០ម |
| ៥៩ | 2.20 | ឈើទាលខ្លូ | Chhoeuteal / Keruing | Dipterocarpus dyeri, Pierre | Dipterocarpaceae | 0.៦០ម |

| | | | | | | |
|---|---|---|---|---|---|---|
| ៦០ | 2.21 | ឈើទាលខ្មៅ ឬឈើទាលទឹក ឬ ឈើទាលបាយ | Chhoeutcal / Keruing | Dipterocarpus alatus, Roxb. | Dipterocarpaceae | 0.៦០ម |
| ៦១ | 2.22 | ឈើទាលប្រេង | Chhoeutcal / Keruing | Dipterocarpus jourdainii, Pierre | Dipterocarpaceae | 0.៦០ម |
| ៦២ | 2.23 | ជ័រចុង | Chhor chong / Meranti | Shorea vulgaris, Pierre | Dipterocarpaceae | 0.៦០ម |
| | | | **លេខរៀង ៣** | | | |
| ៦៣ | 3.1 | ចេកទុំ | Chektum / Medang | Cinnamomum litsaefolium, Thw. | Lauraceae | 0.៣០ម |
| ៦៤ | 3.2 | ក្ដុល | Kdol | Sarcocephalus cordatus, Mig. | Rubiaceae | 0.៣០ម |
| ៦៥ | 3.3 | ខ្ទឹង | Khchung / Bintangor / Poon | Calophyllum inophyllum, L. | Guttiferae | 0.៣០ម |
| ៦៦ | 3.4 | កោងកាង | Kongkang / Poga | Rhizophora mucronata, Poir. | Rhizophoraceae | 0.៣០ម |
| ៦៧ | 3.5 | ក្របៅ | Krabau | Hydnocarpus anthelmintica, Pierre | Flac[illegible] | 0.៣០ម |
| ៦៨ | 3.6 | ក្រាយស | Kray sar / Kokko | Albizia thorelii, Pierre | Mimosaceae | 0.៣០ម |
| ៦៩ | 3.7 | ក្រាស | Kras | Quassia Harmandiana, (Pierre) Noot. | Simaroubaceae | 0.៣០ម |
| ៧០ | 3.8 | ល្ងៀង | Longeang | Cratoxylon prunifolium, Dyer. | Hypericaceae | 0.៣០ម |
| ៧១ | 3.9 | ផ្ទុង | Phaong / Bintangor / Poon | Callophyllum sp. | Guttiferae | 0.៣០ម |
| ៧២ | 3.10 | ព្រីង "គ្រប់ប្រភេទ" | Pring / Kelat | Eugenia spp. | Myrtaceae | 0.៣០ម |
| ៧៣ | 3.11 | ព្រូស | Prous / Bintangor / Poon | Gercinia ferrea, Pierre | Guttiferae | 0.៣០ម |
| ៧៤ | 3.12 | ស្មាច់ | Smach / Kelat | Melaleuca leucadendron, L. | Myrtaceae | 0.៣០ម |
| ៧៥ | 3.13 | ត្រប់ទុំ | Troptum | Xanthophyllum Colubrinum, Gagn. | Xanthophyllaceae | 0.៣០ម |
| ៧៦ | 3.14 | បាយពួរាំង | Baypouvang / Katon | Aglaia spectabilis, S.K. Jain & Benn | Meliaceae | 0.៣០ម |
| ៧៧ | 3.15 | អាទាំង ឬ រទាំង | Ataing | Homalium brevidens, Gagnep | Flacourtiaceae | 0.៣៥ម |
| ៧៨ | 3.16 | ចន្ទន៍ក្រស្នា | Chankrasna / Sandal | Aquilaria crassna, Pierre | Thymelaeaceae | 0.៣៥ម |
| ៧៩ | 3.17 | បង្គៅ | Bangkow / Segera | Aglaia cambodiana, Pierre | Meliaceae | 0.៣៥ម |
| ៨០ | 3.18 | ប្រាំដំឡឹង | Pramdamloeng / Ketepang / Chuglam | Terminalia mucronata, Graib et Huth | Combretaceae | 0.៤០ម |

| | | | | | | |
|---|---|---|---|---|---|---|
| ៨១ | 3.19 | ចាន់ទំពាំង | Chantampang / Kelumpang | Sterculia alata, Roxb. | Sterculiaceae | 0.៤៥ម |
| ៨២ | 3.20 | ចង្គូរធ្មាត | Changourthmat | Vitex pinnata, L. | Verbenaceae | 0.៤៥ម |
| ៨៣ | 3.21 | កណ្ដោល | Kandaul | Careya sphaerica, Pierre | Moraceae | 0.៤៥ម |
| ៨៤ | 3.22 | ខ្នុរព្រៃ | Khnorpreiy / Keledan | Artocarpus asperula, Gagn. | Moraceae | 0.៤៥ម |
| ៨៥ | 3.23 | កំពីងរាជ | Kampingreach | Sandoricum indicum, Cav. | Meliaceae | 0.៤៥ម |
| ៨៦ | 3.24 | ស្មាក្របី | Smakarbei / Penarahan | Knema corticosa, Lour. | Myristicaceae | 0.៤៥ម |
| ៨៧ | 3.25 | ស្វាយព្រៃ | Svayprei / Machang | Mangifera duperreana, Pierre | Anacardiaceae | 0.៤៥ម |
| ៨៨ | 3.26 | តួ | Taour / Ketapan | Terminalia cambodiana, Gagn. | Combretaceae | 0.៤៥ម |
| ៨៩ | 3.27 | ធ្លក | Thlork | Parinarium annamensis, Hance | Rosaceae | 0.៤៥ម |
| ៩០ | 3.28 | ត្រមូង | Tramoung | Garcinia oliveri, Pierre | Guttiferae | 0.៤៥ម |
| ៩១ | 3.29 | ត្រមែង | Trameng / Poga | Carallia lucida, Roxb. | Rhizophoraceae | 0.៤៥ម |
| ៩២ | 3.30 | ស្វាយចំរៀង | Svaychamreang / Merbauh | Swintonia pierrei, Hance | Anacardiaceae | 0.៤៥ម |
| ៩៣ | 3.31 | សំពង់ | Sampong | Tetrameles nudiflora, R.Br. | Datiscaceae | 0.៦០ម |

## ឧបសម្ព័ន្ធ II ភ្ជាប់ប្រកាសលេខ ..០៣៧..ក.ស.ក.ប្រ.ក.ស.ក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

### ប្រភេទឈើមានដោយកម្រ

| លរ | លេខកូដ | ឈ្មោះខ្មែរ | ឈ្មោះពាណិជ្ជកម្ម ក្នុងស្រុក ឬ តំបន់ | ឈ្មោះវិទ្យាសាស្ត្រ | |
|---|---|---|---|---|---|
| | | | | ប្រភេទ | អំបូរ |
| ១ | 0.1 | អង្កាញ់ | Angkanh / Cassia | Cassia siamea, Lam. | Caesalpiniaceae |
| ២ | 0.2 | អង្កត់ខ្មៅ | Angkat khmau / Kayu Malam / Ebony | Diospyros bejaudi, Lec. | Ebenaceae |
| ៣ | 0.3 | បេង | Beng / Afzelia | Afzelia xylocarpa, (Kurz) Craib | Caesalpiniaceae |
| ៤ | 0.4 | ឈើខ្មៅ | Chhoeu khmau / Kayu Malam / Ebony | Diospyros sp. | Ebenaceae |
| ៥ | 0.5 | ជើងចាប | Choeng chap / Mempisang / Karai | Dasymachalon lomentaceum, Fin.& Gagn. | Annonaceae |
| ៦ | 0.6 | ច្រេស | Chres / Albizia | Albizia lebbeck, (L.) Benth | Mimosaceae |
| ៧ | 0.7 | ហៃសាន ឬ ចាន់សរ | Haisan / Chansor | Cassia garrettiana, Craib | Caesalpiniaceae |
| ៨ | 0.8 | ហ៊ុនដាង ឬ ម្រះព្រៅភ្នំ | Hundang / Mreah prau phnom / Cedar white | Dysoxylum loureiri, Pierre | Meliaceae |
| ៩ | 0.9 | ក្រញូង | Kranhung / Tulipwood / Burma | Dalbergia cochinchinensis, Pierre | Papilionaceae |
| ១០ | 0.10 | ក្រៀល | Kroeul / Rengas / Machang | Melanorrhoea laccifera, Pierre | Anacardiaceae |
| ១១ | 0.11 | នាងនួន ឬ លាំង | Neang noun / Camlai / Tulipwood / Burma | Dalbergia bariensis, Pierre | Papilionaceae |
| ១២ | 0.12 | តាត្រាវ | Tatrao / Tembusu / Anan | Fagraea fragrans, Roxb. | Loganiaceae |
| ១៣ | 0.13 | ធ្នង់ | Thnong / Padauk | Pterocarpus pedatus, Pierre | Papilionaceae |
| ១៤ | 0.14 | ត្រយឹង | Trayoeung / Kayu Malam / Ebony | Diospyros helferi, C.B.Clarke | Ebenaceae |
| ១៥ | 2.12 | ស្រល់ | Sral / Pine | Pinus merkusii, Jungh & de Vries | Pinaceae |

## ឧបសម្ព័ន្ធទី III ភ្ជាប់ប្រកាសលេខ ....០.៨.៥.ប្រ.កសក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

### ប្រភេទឈើដែលប្រជាជនមូលដ្ឋានចោះយកជ័រតាមប្រពៃណី

| ល.រ | លេខកូដ | ឈ្មោះខ្មែរ | ឈ្មោះពាណិជ្ជកម្ម ក្នុងស្រុក ឬ តំបន់ | ឈ្មោះវិទ្យាសាស្ត្រ | |
|---|---|---|---|---|---|
| | | | | ប្រភេទ | អំបូរ |
| ១ | 1.13 | ផ្ចឹក | Phchek / Meranti / Balau | Shorea obtusa, Woll. | Dipterocarpaceae |
| ២ | 1.24 | ពពេល | Popel / Giam / Merawan | Shorea roxburgshii, G.Don. | Dipterocarpaceae |
| ៣ | 2.2 | ច្រម៉ាស់ | Chramas / Resak | Vatica astrotricha, Dyer. | Dipterocarpaceae |
| ៤ | 2.15 | ត្បែង | Thbeng / Keruing | Dipterocarpus obtusifolius, Teysm. | Dipterocarpaceae |
| ៥ | 2.17 | ខ្លុង | Khlong / Keruing | Dipterocarpus tuberculatus, Roxb. | Dipterocarpaceae |
| ៦ | 2.18 | ត្រាច | Trach / Keruing | Dipterocarpus intricatus, Dyer. | Dipterocarpaceae |
| ៧ | 2.19 | ឈើទាលបង្គួយ ឬ ឈើទាលនាងវែង | Chhoeuteal / Keruing | Dipterocarpus costatus, Gaertn. | Dipterocarpaceae |
| ៨ | 2.20 | ឈើទាលឆ្នូ | Chhoeuteal / Keruing | Dipterocarpus dyeri, Pierre | Dipterocarpaceae |
| ៩ | 2.21 | ឈើទាលខ្សៀ ឬ ឈើទាលទឹក ឬ ឈើទាលបាយ | Chhoeuteal / Keruing | Dipterocarpus alatus, Roxb. | Dipterocarpaceae |
| ១០ | 2.22 | ឈើទាលប្រេង | Chhoeuteal / Keruing | Dipterocarpus jourdainii, Pierre | Dipterocarpaceae |
| ១១ | 2.23 | ជ័រចុង | Chhor chong / Meranti | Shorea vulgaris, Pierre | Dipterocarpaceae |

## ឧបសម្ព័ន្ធទី IV ភ្ជាប់ប្រកាសលេខ .០៩៥..ប្រក.កសក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០៥
## ប្រភេទឈើផ្តល់ជ័រមានតម្លៃ និង ផ្តល់ខ្លឹមជ័រឈើក្រ

| ល.រ | លេខកូដ | ឈ្មោះខ្មែរ | ឈ្មោះពាណិជ្ជកម្ម ក្នុងស្រុក ឬ តំបន់ | ឈ្មោះវិទ្យាសាស្ត្រ | |
|---|---|---|---|---|---|
| | | | | ប្រភេទ | អំបូរ |
| ១ | 2.7 | ខ្ជូវ . កំលែង ឬ ផ្ចឹកឧត្តម | Khchov / Komleng / Phchek audom / Meranti | Shorea thorelli, Pierre | Dipterocarpaceae |
| ២ | 3.16 | ចន្ទន៍ក្រស្នា | Chankrasna / Sandal | Aquilaria crassna, Pierre | Thymeleaceae |
| ៣ | NC | ដើមមី | Doeumny | Palaquium obovatum, (Griff.) Engler | Sapotaceae |
| ៤ | NC | រង្គ | Rung | Garcinia handburyi, Hook. f. | Guttiferae |
| ៥ | NC | ជ្រៃ | Chrey | Ficus sp. | Moraceae |
| ៦ | NC | សង្កែ | Sangke | Combretum quadrangulare, Kurz. | Combretaceae |
| ៧ | NC | ស្នួល | Snuol | Dalbergia nigrescens, Kurz. | Papilionaceae |
| ៨ | NC | ត្រាំង | Trang | Ficus altissima, Blume | Moraceae |
| ៩ | NC | ពង្រ | Pungro | Schleicheria trijuga, Willd. | Sapindaceae |
| ១០ | NC | សាលព្រឹក្ស | Salproeuk | Couroupita guianensis, Aublet | Lecythidaceae |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក ស ក

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ : ០៩០ ប្រក កសក

# ប្រកាស

## ស្តីពី

## គំរូសំណាបិទភ្ជិតលើខុនថែនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ករម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/ករម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះ នាយកដ្ឋាន រុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៩០៩ ប្រក.កសក.ប្ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ ១ :** ប្រកាសនេះ កំណត់ការបង្កើត ការប្រើប្រាស់គំរូសំណាបិទភ្ជិត និងនីតិវិធីនៃការត្រួតពិនិត្យ និងកិបសំណាបិទភ្ជិតលើខុនថៃនណើផ្ទុកផល អនុផលព្រៃឈើនាំចេញ ដើម្បីធានាបាននូវការគ្រប់គ្រង និងទទួលខុសត្រូវរបស់រដ្ឋបាលព្រៃឈើក្នុងការនាំចេញផលអនុផលព្រៃឈើ ប្រកបដោយប្រសិទ្ធភាព។

**ប្រការ ២ :** អនុញ្ញាតឱ្យរដ្ឋបាលព្រៃឈើបង្កើត និងប្រើប្រាស់គំរូសំណាបិទភ្ជិតលើខុនថៃនណើផ្ទុកផល អនុផលព្រៃឈើនាំចេញ ដែលមានរាងមូលសំប៉ែតមានអង្កត់ផ្ចិតមាត្រ ៤០មម និងកំរាស់ ៥មម។ សំណាបិទភ្ជិតនេះ បន្ទាប់ពីបានកិបបិទភ្ជិតលើខុនថៃនណើដោយដង្កាប់កិបរួចមក នឹងលេចចេញនូវរូបភាពជាសញ្ញាសំគាល់មានទំរង់ដូចរាងនៃសញ្ញាសំគាល់របស់រដ្ឋបាលព្រៃឈើ និងនៅលើផ្ទៃម្ខាងផ្នែកខាងមុខមានបង្ហាញអក្សរកាត់ថា រ.ព ស្ថិតនៅចំកណ្តាល និងនៅពីក្រោមមានលេខសំគាល់ ០១ ឬ ០២ រហូតដល់លេខ ០៩ និងនៅលើផ្ទៃម្ខាងទៀតផ្នែកខាងក្រោយមានសញ្ញាសំគាល់ដោយរូបដើមឈើមួយដើមនៅចំកណ្តាល ព្រមទាំងមានអមដោយញញួរត្រារដ្ឋបាលព្រៃឈើចំនួនពីរ ដាក់ខ្វែងគ្នាស្ថិតនៅផ្នែកគល់នៃដើមឈើ ដូចមានកំណត់ក្នុង ***ឧបសម្ព័ន្ធទី ១*** នៃប្រកាសនេះ។

**ប្រការ ៣ :** រាល់ផល អនុផលព្រៃឈើនាំចេញដែលផ្ទុកក្នុងខុនថៃនណើ ចាំបាច់ត្រូវមានការត្រួតពិនិត្យ និងបិទសំណាភ្ជិតជាមុន ដោយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច នៅមុនពេលអនុញ្ញាតដឹកជញ្ជូនទៅកាន់ឃ្លាំង ឬទីលានបញ្ចេញទំនិញពីគយ ។

ខុនថៃនណើផ្ទុកផល អនុផលព្រៃឈើនាំចេញ គឺសំដៅទៅលើសំបកធុងគ្រប់ប្រភេទ ដែលអាចផ្ទុកផល អនុផលព្រៃឈើ ស្របតាមស្តង់ដា ដោយធានាគុណភាព និងសុវត្ថិភាព ។

**ប្រការ ៤ :** មន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ចចុះត្រួតពិនិត្យ និងបិទសំណាភ្ជិតលើខុនថៃនណើផ្ទុកផល អនុផលព្រៃឈើនាំចេញ ត្រូវធ្វើកំណត់ហេតុស្របតាមគំរូ ដូចបានកំណត់ក្នុង ***ឧបសម្ព័ន្ធទី ២*** នៃប្រកាសនេះ ។

ការត្រួតពិនិត្យ និងបិទសំណាភ្ជិតលើខុនថៃនណើផ្ទុកផល អនុផលព្រៃឈើនាំចេញ អាចប្រព្រឹត្តទៅបានលុះត្រាតែមានអាជ្ញាប័ណ្ណនាំចេញ ដែលមានចុះទិដ្ឋាការដោយរដ្ឋបាលព្រៃឈើ ឬមានគោលការណ៍អនុញ្ញាតនាំចេញរបស់រាជរដ្ឋាភិបាលហើយត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ នាំចេញ ដែលផ្តល់ដោយប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៥ :** ការស្នើសុំកាត់ចេញនូវសំណាដែលបានបិទភ្ជិតរួច ដោយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចលើខុនថៃនណើផ្ទុកផល អនុផលព្រៃឈើនាំចេញ ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញដោយមូលហេតុណាមួយចាំបាច់ អាចប្រព្រឹត្តទៅបានលុះត្រាមានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ឬរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៦ :** ការផ្ទុក និងដឹកជញ្ជូននាំចេញផល អនុផលព្រៃឈើតាមខុនថៃនណើ ដោយពុំមានការត្រួតពិនិត្យ និងបិទសំណាភ្ជិតជាមុនពីមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ឬមានកិបសំណាបិទភ្ជិតដែលខុសពីនីតិវិធីរបស់រដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាល្មើសច្បាប់ ។

ក្នុងករណីសំណាបិទភ្ជិតលើខុនថៃនឈើផ្ទុកជល អនុផលព្រៃឈើនាំចេញ មានភាពមិនប្រក្រតីដូចជា បែក បាក់ ឬ ដាច់ ដែលមានមូលហេតុច្បាស់លាស់ ម្ចាស់ទំនិញចាំបាច់ត្រូវរាយការណ៍មកមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច នៅនឹងកន្លែងជាបន្ទាន់ ដើម្បីសុំវិធានការពីប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៧ :** ជនណាមានចេតនាធ្វើឱ្យខូច-ដាច់ ឬ បែកបាក់សំណាបិទភ្ជិតដែលគឺបរួចលើខុនថៃនឈើផ្ទុកជល អនុផលព្រៃឈើនាំចេញដោយរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ក្នុងគោលបំណងផ្លាស់ប្តូរ ឬ បន្ថែមទំនិញផ្ទុយពីអាជ្ញាប័ណ្ណនាំចេញ ឬ លិខិតអនុញ្ញាតដឹកជញ្ជូនចេញ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ ៨ :** ជនណាបង្កើត ប្រើប្រាស់ ឬ ក្លែងបន្លំសំណាបិទភ្ជិត លើខុនថៃនឈើផ្ទុកជល អនុផលព្រៃឈើនាំចេញ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ ៩ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និង ប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កុម្ភៈឆ្នាំ ២០០៥

រដ្ឋមន្ត្រី

ច័ន្ទ.សារុន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- ទីចាត់ការគយ និងរដ្ឋាករ
- នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្រ្កាបការក្លែងបន្លំ ( កាំកុងត្រូលកម្ពុជា)
- ដូចប្រការ ៩
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១ ភ្ជាប់ប្រកាសលេខ....០៥៨ ប្រក.កសក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

**សញ្ញាសំគាល់ញញួរបិទត្រាលើគល់ឈើដែលកាប់**

**សម្រាប់ បិទត្រាលើឈើដែលត្រូវបានអនុញ្ញាតឲ្យកាប់**




**សញ្ញាសំគាល់ផ្ទៃញញួរផ្នែកខាងមុខ**



**សញ្ញាសំគាល់ផ្ទៃញញួរផ្នែកខាងក្រោយ**

ឧបសម្ព័ន្ធទី ២ ភ្ជាប់ប្រកាសលេខ ០៩០ ប្រ.កសក. ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលព្រៃឈើ**

# កំណត់ហេតុ

# ស្តីពី

# ការត្រួតពិនិត្យ និងកិបសំណាបិទត្រា លើខ្លួនថែនឈើផ្ទុកផល អនុផលព្រៃឈើនាំចេញ

ឆ្នាំ.................................................... ខែ.............. ថ្ងៃទី.................... វេលាម៉ោង...........................

នៅទីតាំង.......................................................................................................................... មានការត្រួតពិនិត្យ និងកិបសំណាបិទត្រាលើខ្លួនថែនឈើផ្ទុកផល អនុផលព្រៃឈើនាំចេញរបស់លោក/លោកស្រី...................................................... ជាប្រធាន/តំណាង........................................................................................ ធ្វើឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដែលមានសមាសភាពចូលរួម និងទទួលបានលទ្ធផលដូចខាងក្រោម:

**១.សមាសភាពមន្ត្រីរដ្ឋបាលព្រៃឈើចូលរួមត្រួតពិនិត្យ**

-លោក.......................................................

-............................................................

-............................................................

-............................................................

**២.ម្ចាស់ ឬតំណាងម្ចាស់ផល អនុផលព្រៃឈើចូលរួម**

-លោក.................................... ប្រធាន/តំណាងក្រុមហ៊ុន....................................................

-..........................................................................................................................

-..........................................................................................................................

-..........................................................................................................................

**៣.លទ្ធផលនៃការត្រួតពិនិត្យ និងកិបសំណាបិទត្រាលើខ្លួនថែនឈើផ្ទុកផល អនុផលព្រៃឈើនាំចេញ**

១.-ខ្លួនថែនឈើលេខ...........................................................................................................

-ផ្ទុកផល អនុផលព្រៃឈើប្រភេទ..........................................................................................

-យថាប្រភេទ..........................................................................................

-បរិមាណ..........................................................................................

-កឹបសំណាបិទភ្ជិតលេខ ស.ត...................... ។

២.-ខុនថៃនឈើលេខ..........................................................................................

-ផ្ទុកផល អនុផលព្រៃឈើប្រភេទ..........................................................................................

-យថាប្រភេទ..........................................................................................

-បរិមាណ..........................................................................................

-កឹបសំណាបិទភ្ជិតលេខ ស.ត...................... ។

៣.-ខុនថៃនឈើលេខ..........................................................................................

-ផ្ទុកផល អនុផលព្រៃឈើប្រភេទ. ..........................................................................................

-យថាប្រភេទ..........................................................................................

-បរិមាណ..........................................................................................

-កឹបសំណាបិទភ្ជិតលេខ ស.ត...................... ។

៤.-ខុនថៃនឈើលេខ..........................................................................................

-ផ្ទុកផល អនុផលព្រៃឈើប្រភេទ..........................................................................................

-យថាប្រភេទ..........................................................................................

-បរិមាណ..........................................................................................

-កឹបសំណាបិទភ្ជិតលេខ ស.ត...................... ។

សរុបខុនថៃនឈើដែលបានត្រួតពិនិត្យ និងកឹបសំណាបិទភ្ជិត មានចំនួន............................................ ខុនថៃនឈើ

សរុបផល អនុផលព្រៃឈើដែលបានផ្ទុកមានបរិមាណ.......................................................................... ។

## ៤.ការបញ្ជាក់ធានារបស់ម្ចាស់ផល អនុផលព្រៃឈើនាំចេញ

ខ្ញុំបាទ នាងខ្ញុំ សូមធានាថាមិនធ្វើឱ្យខូចខាត បែកបាក់ ឬដាច់ សំណាបិទភ្ជិតលើខុនថៃនឈើផ្ទុកផល អនុផលព្រៃឈើនាំចេញរបស់រដ្ឋបាលព្រៃឈើក្នុងគោលបំណងផ្លាស់ប្ដូរ ឬបន្ថែមទំនិញផ្ទុយពីលិខិតអនុញ្ញាតនាំចេញឡើយ ។ ក្នុងករណី ខ្ញុំបាទ នាងខ្ញុំ ប្រព្រឹត្តផ្ទុយពីការធានាខាងលើនេះ ខ្ញុំបាទ នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ។

ការត្រួតពិនិត្យ និង កឹបសំណាបិទភ្ជិតលើខុនថៃនឈើផ្ទុកផលអនុផលព្រៃឈើនាំចេញរបស់លោក/លោកស្រី............ ........................................ ប្រធាន/តំណាងក្រុមហ៊ុន ..........................................................................................

បានអនុវត្តចប់សព្វគ្រប់នៅវេលាម៉ោង .............................. នាថ្ងៃទី............ខែ............ ឆ្នាំ................. ។

**លិខិតភ្ជាប់** :-អាជ្ញាប័ណ្ណនាំចេញលេខ............ ពកប.ន ចុះថ្ងៃទី ........ ខែ..........ឆ្នាំ ........ ។

-លិខិតគោលការណ៍អនុញ្ញាតនាំចេញផល អនុផលព្រៃឈើលេខ................................. ចុះថ្ងៃទី ........ ខែ..........ឆ្នាំ ..........

-លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញលេខ................................. ចុះថ្ងៃទី ........... ខែ..........ឆ្នាំ ..........

-បញ្ជីផល អនុផលព្រៃឈើនាំចេញ ។

**អ្នកធ្វើកំណត់ហេតុ**

**ម្ចាស់ផល អនុផលព្រៃឈើនាំចេញ**

**មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រួតពិនិត្យ**

បានឃើញ និងបញ្ជូនមក

លោកប្រធានរដ្ឋបាលព្រៃឈើ

"ដើម្បីមេត្តាពិនិត្យ សំរេច"

រាជធានីភ្នំពេញ, ថ្ងៃទី........ខែ...........ឆ្នាំ ... . .....

**ប្រធានការិយាល័យអភិវឌ្ឍន៍ឧស្សាហកម្ម និងពាណិជ្ជកម្មព្រៃឈើ**

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ...........ឆ្នាំ ...........

**ប្រធានរដ្ឋបាលព្រៃឈើ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៥៤ ពណ.ចំនក

ភ្នំពេញថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **បេសស្ដារី ខ្វលឡីធី មីត (ខេមបូឌា) ខូ អិលធីឌី**

**BESTARI QUALITY MEAT ( CAMBODIA ) CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2209/05E ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៥

មានទម្រង់ជា : ក្រុមហ៊ុនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក ABDULLAH BIN MANSOR ប្រធានក្រុមប្រឹក្សាភិបាល

លោក **សេន ចាវពល** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១០ ផ្លូវលេខ ៨៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេសគ្រឿងឧបភោគបរិភោគ ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការដួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការដូសដុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្ដូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សព្វផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងទទួលបញ្ញើ

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម្លងជូន

